ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**នាយកដ្ឋានអឺរ៉ុប**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃសម័យប្រជុំលើកទី ៤ នៃកិច្ចពិគ្រោះយោបល់ទ្វេភាគី កម្ពុជា-ស៊ែប៊ី រវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការបរទេស នៃសាធារណរដ្ឋស៊ែប៊ី

នាព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៤ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំធ្វើជាសហប្រធានដោយ **ឯកឧត្តម យួន ផុនរតនៈ** រដ្ឋលេខាធិការ និងក្រសួងការបរទេស នៃសាធារណរដ្ឋស៊ែប៊ី ដឹកនាំធ្វើជាសហប្រធានដោយ **ឯកឧត្តម Damjan Jović** រដ្ឋលេខាធិការ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី៤ ប្រកបដោយជោគជ័យ និងផ្លែផ្កា នៅរាជធានីភ្នំពេញ។ ព្រឹត្តិការណ៍ដ៏សំខាន់នេះ គឺជាសក្ខីភាពមួយចំពោះការប្តេជ្ញាចិត្តដ៏ខ្ជាប់ខ្ជួនរបស់ប្រទេសទាំងពីរក្នុងការជំរុញកិច្ចសន្ទនាជាទៀងទាត់ ការពង្រឹងទំនាក់ទំនងប្រពៃណី និងយូរអង្វែងរបស់ប្រទេសទាំងពីរ និងបង្ហាញពីចក្ខុវិស័យក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ ដោយបានលើកឡើងពីសារៈសំខាន់នៃគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រដើម្បីជំរុញការអភិវឌ្ឍ និងវិបុលភាពទៅវិញទៅមក។

**ឯកឧត្តម យួន ផុនរតនៈ** បានលើកឡើងពីវឌ្ឍនភាពដ៏គួរឱ្យកត់សម្គាល់របស់កម្ពុជាក្នុងរយៈពេល ២៥ឆ្នាំកន្លងមក រួមទាំងស្ថិរភាពនៃកំណើនផលិតផលសរុប ការកាត់បន្ថយភាពក្រីក្រ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗដូចជា ព្រែកជីកហ្វូណនតេជោ និងអាកាសយានដ្ឋានអន្តរជាតិតេជោ។ល។ **ឯកឧត្តម Damjan Jović** បានចែករំលែកពីសមិទ្ធិផលរបស់ស៊ែប៊ី ក្នុងនាមជាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនលឿនបំផុតមួយនៅទ្វីបអឺរ៉ុប ដែលត្រូវបានជំរុញដោយភាពជឿនលឿននៃបច្ចេកវិទ្យា ការអប់រំ និងថាមពលកកើតឡើងវិញ។ ភាគីទាំងពីរបានគូសបញ្ជាក់ពីសារៈសំខាន់នៃសន្តិភាព និងស្ថិរភាពដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបានចែករំលែកយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមនៅក្នុងប្រទេស។

ដើម្បីពង្រឹងភាពជាដៃគូឱ្យកាន់តែរឹងមាំថែមទៀត ភាគីទាំងពីរបានលើកឡើងពីអាទិភាពនៃកិច្ចសន្ទនាកម្រិតខ្ពស់ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ជំរុញទំនាក់ទំនងរវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាលនៃប្រទេសទាំងពីរ ឱ្យកាន់តែជិតស្និទ្ធ ដើម្បីត្រួសត្រាយផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីយូរអង្វែង និងប្រកបដោយផ្លែផ្កា។ ភាគីទាំងពីរ ក៏បានបញ្ជាក់ពីការត្រៀមស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការទៅវិញទៅមកនានា ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តក្នុងការពង្រឹងចំណងមិត្តភាព។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ឯកឧត្តម ឃួន ផុនរតនៈ បានឆ្លៀតឱកាសនោះ ជម្រាបអំពីយុទ្ធសាស្ត្របញ្ចកោណរបស់កម្ពុជា ដែលផ្តោតលើការអភិវឌ្ឍធនធានមនុស្ស បរិវត្តកម្មឌីជីថល និងកំណើនហេដ្ឋារចនាសម្ព័ន្ធ ដែលជាមូលដ្ឋានគ្រឹះនៃវឌ្ឍនភាពរបស់កម្ពុជា។ ឯកឧត្តម Damjan Jović បានគូសបញ្ជាក់អំពីជំនាញរបស់សែប៊ី ក្នុងវិស័យនវានុវត្តន៍បច្ចេកវិទ្យា គម្រោងថាមពលកកើតឡើងវិញ និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានវិទ្យា ដែលជាវិស័យកិច្ចសហប្រតិបត្តិការប្រទេសទាំងពីរអាចទទួលបានផលប្រយោជន៍រួម។ ដោយទទួលស្គាល់ពីអាទិភាពទាំងនេះ ភាគីទាំងពីរបានប្តេជ្ញាស្វែងរកពេលវេលាសមស្រប ដើម្បីចុះហត្ថលេខាលើឯកសារសំខាន់ៗដែលនឹងត្រួសត្រាយផ្លូវសម្រាប់ភាពជាដៃគូកាន់តែរឹងមាំ និងសមាហរណកម្មកាន់តែច្រើន។

សហប្រធានទាំងពីរបានទទួលស្គាល់សក្តានុពលនៃការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការពង្រឹងពាណិជ្ជកម្ម និងការវិនិយោគ។ ឯកឧត្តម ឃួន ផុនរតនៈ បានលើកឡើងពីភាពអំណោយផលនៃច្បាប់វិនិយោគកម្ពុជា ដែលអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិ ១០០% ក្នុងវិស័យជាច្រើន ស្របពេល ដែលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ថាមពលកកើតឡើងវិញ និងឌីជីថលនីយកម្ម បាននិងកំពុងអភិវឌ្ឍន៍។ ឯកឧត្តម Damjan Jović បានចែករំលែកជំនាញរបស់សែប៊ីក្នុងភាពជាដៃគូ រវាងវិស័យសាធារណៈ - ឯកជន និងបានបង្ហាញពីការត្រៀមខ្លួនជាស្រេច ក្នុងការស្វែងរកមធ្យោបាយសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការនេះ។ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ ភាគីទាំងពីរបានព្រមព្រៀងគ្នាពិនិត្យលទ្ធភាពបង្កើតយន្តការប្រកបដោយប្រសិទ្ធភាពផ្សេងៗ និងជំរុញភាពជាដៃគូរវាងធុរកិច្ច និងធុរកិច្ច។ គំនិតផ្តួចផ្តើមទាំងនេះមានគោលបំណងបង្កើតបរិយាកាសអំណោយផលសម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម។ គួរកត់សម្គាល់ថា គណៈប្រតិភូធុរកិច្ចសែប៊ី គ្រោងនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជានៅដើមខែធ្នូខាងមុខ ដើម្បីស្វែងយល់ពីគម្រោងសក្តានុពល និងភាពជាដៃគូបន្ថែមទៀត។

បន្ថែមលើការពិភាក្សាលើកិច្ចសហប្រតិបត្តិការទ្វេភាគី សហប្រធានទាំងពីរក៏បានពិភាក្សាលើបញ្ហាតំបន់ និងពិភពលោកដែលជាកង្វល់រួមគ្នា។ ភាគីទាំងពីរបានអះអាងសាជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នា សម្រាប់កិច្ចសហប្រតិបត្តិការក្នុងវេទិកាអន្តរជាតិ ដោយគូសបញ្ជាក់ពីសារៈសំខាន់នៃការយោគយល់គ្នា និងសាមគ្គីភាពដែលជាមូលដ្ឋានសម្រាប់ភាពជាដៃគូដ៏រឹងមាំ និងយូរអង្វែង។

កិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី៤នេះ គឺជាព្រឹត្តិការណ៍សំខាន់មួយសម្រាប់ទំនាក់ទំនងរវាងកម្ពុជា និងសែប៊ី។ ភាគីទាំងពីរបានបង្ហាញពីការតាំងចិត្តយ៉ាងច្បាស់លាស់ក្នុងការប្រែក្លាយការសន្ទនាទៅជាសកម្មភាពជាក់ស្តែង ដោយប្រើប្រាស់កម្លាំងរួមគ្នា ដើម្បីជំនះឧបសគ្គ និងសម្រេចបាននូវវិបុលភាពរួម។

ថ្ងៃចន្ទ ០២ កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៤